## ហេតុអ្វីបានជារដ្ឋាភិបាលរដ្ឋជួយប្រាក់ដល់កម្មវិធីមត្តេយ្យសាលា?

ការស្រាវជ្រាវបង្ហាញថាការរៀនសូត្រនៅបឋមវ័យចាក់គ្រឹះសំរាប់ការរៀនសូត្រនៅពេលក្រោយ ហើយកម្មវិធីមត្តេយ្យសាលាដែលមានគុណភាពល្អជួយធ្វើឲ្យការរៀនសូត្របន្តបន្ទាប់ក្រោយមក សុខភាពនិងចរិយាឲ្យបានប្រសើរឡើងទៀតដោយមានឥទ្ធិពលដ៏ល្អចូលទៅក្នុងជីវិតអ្នកពេញវ័យ។

រដ្ឋាភិបាលវិចតូរិយ៉ាជួយប្រាក់ដល់កិច្ចបំរើមួយចំនួនធំដែលផ្តល់នូវកម្មវិធីមត្តេយ្យសាលាដល់ការគាំទ្រការរៀនសូត្រដ៏សំខាន់នៅបឋមវ័យដែល:

- ចាក់គ្រឹះសំរាប់ការរៀនសូត្រនៅពេលក្រោយទៀត
- រៀបចំកុមារទៅរកផ្លូវជោគជ័យនៃការអប់រំ ការងារនិងជីវិតនៅថ្ងៃក្រោយ។

អ្វីៗដែលកើតមានឡើងដល់កូនលោកអ្នកនៅក្នុងបឋមវ័យនោះ អាចប៉ះពាល់ដល់របៀបដែលខួរក្បាលគេលូតលាស់។

## តើកូនខ្ញុំនឹងរៀនអ្វីខ្លះ?

បទពិសោធន៍នៃមត្តេយ្យសាលាផ្តល់កូនលោកអ្នកនូវឱកាសដើម្បី:

- ធ្វើឲ្យលូតលាស់ខាងការប៉ិនប្រសប់ក្នុងការទាក់ទងគ្នានិងការប៉ិនប្រសប់ដែលជួយការអាននិងការសរសេរផង
- ធ្វើឲ្យលូតលាស់ខាងការទទួលខុសត្រូវនិងឯករាជ្យភាព ការកើនឡើងនៃការទុកចិត្ត និងអារម្មណ៍នៃគុណសម្បត្តិរបស់ខ្លួនផង
- រៀនការប៉ិនប្រសប់ខាងសង្គម ដូចជាការស្តាប់និងការគោរពយោបល់របស់អ្នកដទៃ
- បង្កើតការយល់ដឹងខ្លួនឯង និងការគោរពចំពោះអ្នកដទៃ
- រៀនឲ្យចេះប្រកបដោយប្រឌិតញាណ
- ធ្វើគណិតសាស្ត្រ ការសិក្សាខាងសង្គម និងវិទ្យាសាស្ត្រ
- ប្រើបច្ចេកវិជ្ជា
- ដឹងការសប្បាយនៃការរៀនសូត្រ
- រកមិត្តភក្តិថ្មីៗ។

## តើខ្ញុំអាចរកកម្មវិធីនៃមេត្តយ្យសាលាតាមរបៀបណាដែរ?

កម្មវិធីនៃមេត្តយ្យសាលាអាចត្រូវបានផ្តល់ជូននៅតាមកន្លែងផ្សេងៗគ្នា ដូចជាមេត្តយ្យសាលានៃសហគមន៍ មជ្ឈមណ្ឌលថែទាំកុមារ ហើយនិងសាលាខ្លះ។

ដើម្បីរកកម្មវិធីនៃមេត្តយ្យសាលាដែលមានគុណភាពល្អនៅក្នុងតំបន់របស់លោកអ្នក សូមបើកមើលវែបសៃ **www.education.vic.gov.au/findakindergarten** ឬទាក់ទងនឹងសាលាសង្កាត់របស់លោកអ្នក។

ទំនាក់ទំនងលំអិតសំរាប់សាលាសង្កាត់លោកអ្នកអាចរកបាននៅវែបសៃដូចតទៅនេះ **www.mav.asn.au** ឬ **www.vicnet.net.au/government/localgovt**

លោកអ្នកក៏អាចបើកមើលវែបសៃរបស់យើងបានផងដែរគឺ **www.education.vic.gov.au/earlychildhood** ឬទូរស័ព្ទទៅកាន់ការិយាល័យសំរាប់ការលូតលាស់កុមារនិងបឋមវ័យនៃកុមារភាពតាមលេខ 1300 731 947 (សំរាប់តម្លៃស្មើនឹងទូរស័ព្ទតំបន់)។

1800 890 400 Amharic
- የአማርኛ አስተርጓሚ አገልግሎት (ነፃ የስልክ ጥሪ)

1800 890 401 Arabic
- للحصول على خدمات مترجم عربي (مكالمة مجانية)

1800 890 403 Cambodian
ចំពោះកិច្ចបំរើនៃអ្នកបកប្រែភាសាខ្មែរ (ទូរស័ព្ទឥតគិតតម្លៃ)

1800 890 404 Cantonese
- 可獲得廣東話傳譯服務（免費電話）

1800 890 402 Dinka
- Tënë Agamthok ë Muɔŋjäŋ (Kënë ee Talapun Cie Yup ë Wëu)

1800 890 406 Filipino
- Para sa serbisyong pang- interprete sa wikang Pilipino (libreng tawag)

1800 890 405 Korean
- 한국어 통역을 원하시면 (무료 통화)

1800 890 409 Macedonian
- За преведувачи на македонски (бесплатен повик)

1800 890 407 Mandarin
- 普通话传译员（免费电话）

1800 890 408 Nuer
- Ni lɔɔrä baaŋ a thil yio̱w (Free call)

1800 890 410 Russian
- Русская переводческая служба (бесплатный звонок)

1800 890 411 Serbian
- За Службу тумача на српском (бесплатан позив)

1800 890 412 Somali
- Adeega mutarjumka ee Soomaalida (lacag laáan)

1800 890 413 Spanish
- Para Servicio de intérpretes en castellano (llamada gratuita)

1800 890 414 Turkish
- Türkçe sözlü tercümanlık hizmeti için (ücretsiz arama)

1800 890 415 Vietnamese
- Dịch vụ thông ngôn bằng tiếng Việt (điện thoại miễn phí)

© រក្សាសិទ្ធិនៃក្រសួងអប់រំ
និងការលូតលាស់បឋមវ័យនៃកុមារភាព ឆ្នាំ2008
បានអនុញ្ញាតដោយរដ្ឋាភិបាលវិចតូរិយ៉ា
50 Lonsdale Street, Melbourne.
ខែតុលា ឆ្នាំ2008

*Khmer*

# តម្លៃទាប ឬឥតគិតថ្លៃមត្តេយ្យសាលា

ប្រាក់ជំនួយខាងឈ្នួល (fee subsidy) មត្តេយ្យសាលា



កូនលោកអ្នកប្រហែលជាមានសិទ្ធិទទួលតម្លៃទាប ឬឥតគិតថ្លៃនៃមត្តេយ្យសាលា ដែលជាភាគមួយនៃប្តេជ្ញាបន្ទរបស់រដ្ឋាភិបាលវិចតូរិយ៉ាចំពោះគុណភាពល្អសំរាប់ការអប់រំបឋមវ័យនៃកុមារភាព។

A Victorian Government initiative

Victoria
The Place To Be

# តើលោកអ្នក ឬកូនលោកអ្នកមានប័ណ្ណ ឬទិដ្ឋាការមួយណាក្នុងចំណោមប័ណ្ណ ឬទិដ្ឋាការទាំងនេះទេ?

លោកអ្នកអាចទាមទារយកប្រាក់ជំនួយខាងឈ្នួលនេះ ប្រសិនបើលោកអ្នកមានប័ណ្ណមួយណាដូចតទៅនេះ:

- ប័ណ្ណថែទាំសុខភាព(Health Care Card)
- ប័ណ្ណសម្បទានចូលនិវិត្ត(Pensioner Concession Card)
- ប័ណ្ណពណ៌មាសនៃក្រសួងកិច្ចការអតីតយុទ្ធជន (Department of Veteran's Affairs Gold Card)
- ទិដ្ឋាការការពារបណ្ដោះអាសន្ន/ទិដ្ឋាការមនុស្សធម៌លេខ 447, 451, 785 និង 786
- ទិដ្ឋាការតភ្ជាប់សំរាប់អ្នកស្វែងរកសិទ្ធិជ្រកអាស្រ័យ A–F
- ទិដ្ឋាការជនភៀសខ្លួននិងមនុស្សធម៌ពិសេស 200–217

ប្រសិនបើលោកអ្នកមានកូនភ្លោះបី ឬកូនភ្លោះបួនរៀននៅមត្តេយ្យសាលានៅឆ្នាំជាមួយគ្នា លោកអ្នកក៏មានសិទ្ធិទទួលយកប្រាក់ជំនួយនេះសំរាប់កូនម្នាក់ៗដែរ។















## តម្លៃទាប ឬឥតគិតថ្លៃនៃមត្តេយ្យសាលា

លោកអ្នកអាចមានសិទ្ធិទទួលបាននូវមត្តេយ្យសាលាឥតគិតថ្លៃ(ឬមត្តេយ្យសាលាដែលមានតម្លៃតិចតួចបំផុត)ប្រសិនបើលោកអ្នកមានសម្បទាន ឬទិដ្ឋាការមួយណាក្នុងចំណោមប័ណ្ណ ឬទិដ្ឋាការខាងលើនេះ ឬលោកអ្នកមានកូនភ្លោះបី ឬកូនភ្លោះបួន រៀននៅមត្តេយ្យសាលានៅឆ្នាំជាមួយគ្នា។

នេះដោយសារថារដ្ឋាភិបាលវិចតូរិយ៉ាជួយប្រាក់ជំនួយខាងឈ្នួលមត្តេយ្យសាលា ដើម្បីផ្ដល់ពេល10ម៉ោងដល់កម្មវិធីមត្តេយ្យសាលាក្នុងមួយអាទិត្យដោយឥតគិតថ្លៃ។ (ប្រសិនបើកម្មវិធីមត្តេយ្យសាលាតំបន់លោកអ្នកផ្ដល់ពេលច្រើនជាង 10ម៉ោងក្នុងមួយអាទិត្យនោះ លោកអ្នកប្រហែលជាទទួលម៉ោងបន្ថែមនោះដោយឥតគិតថ្លៃ ឬ លោកអ្នកប្រហែលជាបង់ប្រាក់ចំពោះម៉ោងបន្ថែមតែប៉ុណ្ណោះ)។

## តើខ្ញុំទទួលប្រាក់ជំនួយខាងឈ្នួលមត្តេយ្យសាលាបានដោយរបៀបណាដែរ?

សូមនិយាយជាមួយបុគ្គលិកនិងបង្ហាញគេនូវប័ណ្ណចុះថ្លៃ ទិដ្ឋាការ សំបុត្រកំណើត ឬឯកសារដែលបានយល់ព្រម* នៅពេលដែលលោកអ្នកកំពុងចុះឈ្មោះកូនលោកអ្នកនៅមត្តេយ្យសាលា ឬនៅដើមឆ្នាំនៃមត្តេយ្យសាលា។

មត្តេយ្យសាលានឹងទាមទារយកប្រាក់ជំនួយខាងឈ្នួលនេះក្នុងនាមលោកអ្នកពីក្រសួងអប់រំនិងការលូតលាស់នៃបឋមវ័យនៃកុមារភាព។ (ប្រាក់ជំនួយនេះត្រូវបានបង់ផ្ទាល់ទៅឲ្យមត្តេយ្យសាលានេះ ដើម្បីឲ្យមត្តេយ្យសាលានេះពុំយកតម្លៃពីកូនលោកអ្នក ឬផ្ដល់នូវការបញ្ចុះតម្លៃយ៉ាងច្រើន)។

លោកអ្នកអាចដាក់ពាក្យសុំយកប្រាក់ជំនួយខាងឈ្នួលមត្តេយ្យសាលានៅពេលណាក៏បាននៅក្នុងអំឡុងឆ្នាំ ទោះបីកូនលោកអ្នកដូរទៅមត្តេយ្យសាលាមួយទៀតក៏ដោយ។ ប្រាក់ជំនួយខាងឈ្នួលនឹងត្រូវបានបង់ឲ្យទាំងអស់ពេញមួយអាណាត្តិដោយមិនគិតអំពីថ្ងៃខែឆ្នាំដែលកូនលោកអ្នកចាប់ផ្ដើមនៅក្នុងអាណាត្តិនេះ។

*ឯកសារដែលបានយល់ព្រមគឺជាលិខិតមួយចេញពីក្រសួងអន្តោប្រវេសន៍និងសញ្ជាតិ ឬហៅថា "ឯកសារធ្វើដំណើរទៅប្រទេសអូស្ត្រាលី" បញ្ជាក់ស្ថានភាពនៃទិដ្ឋាការ។

## តើមត្តេយ្យសាលាទទួលប្រាក់ជំនួយដោយរបៀបណាដែរ?

រដ្ឋាភិបាលវិចតូរិយ៉ាផ្ដល់ប្រាក់ជំនួយដល់កិច្ចបំរើមួយចំនួនធំដែលផ្ដល់នូវកម្មវិធីមត្តេយ្យសាលាដល់កុមារទាំងឡាយ។ ប្រាក់ជំនួយនេះជួយផ្ដល់តម្លៃនៃការផ្ដល់កម្មវិធីមត្តេយ្យសាលា។ កិច្ចបំរើនៃមត្តេយ្យសាលាលោកអ្នកទទួលខុសត្រូវខាងដាក់កំរិតនៃឈ្នួលនេះ។

រកមើលវិញ្ញាបនប័ត្រមត្តេយ្យសាលានេះនៅពេលជ្រើសរើសកម្មវិធីមត្តេយ្យសាលាសំរាប់កូនលោកអ្នក។




វិញ្ញាបនប័ត្រនេះបង្ហាញថាកម្មវិធីមត្តេយ្យសាលាត្រូវបានបង្កើតនិងផ្ដល់ដោយគ្រូដែលមានជំនាញខាងបឋមវ័យនៃកុមារភាព ហើយត្រូវបានផ្ដល់ប្រាក់ដោយរដ្ឋាភិបាលផង។

ចំពោះព័ត៌មានថែមទៀតអំពីប្រាក់ជំនួយខាងឈ្នួលមត្តេយ្យសាលា សូមបើកមើលវេបសៃ
**www.education.vic.gov.au/kindergarten/feesubsidy**